**សកម្មភាព** ៖ **ល្បែងបង្កើតឧបករណ៍តន្ត្រី**

(ល្បែងបង្កើតឧបករណ៍តន្ត្រីនេះ ទុកសម្រាប់លេងនៅក្នុង **“ល្បែងលេងឧបករណ៍តន្ត្រី”**)

**សិក្សាសង្គម**

គំនូរ និងសកម្មភាពកសាង (ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)។

ការលើកតម្កើនវប្បធម៌ (ការលើកតម្កើនវប្បធម៌របស់ខ្លួន)។

**គោលបំណង** ៖

**(សិក្សាសង្គម)** ប្រាប់ពីរបៀប បិទ គូរ រចនា បង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលបង្កើតឡើងបាន។

ប្រាប់បានពីរបៀបសូនរូបជារាងងាយៗដោយប្រើដៃទាំងពី។

បង្ហាញពីឧបករណ៍ភ្លេងខ្មែរដូចជា ស្គរ ខ្លុយ ចង្រ្កឹង ការចៃ ការឡុក ហ្គីតា ផ្លុំទឹកក្នុងដប។

**កម្រិតសិក្សា** ៖ ទាប មធ្យម ខ្ពស់

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង "តើអ្នកចង់ធ្វើការងារអ្វី?"

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ប្រមូលសម្ភារដែលត្រូវប្រើសម្រាប់បង្កើតជាឧបករណ៍តន្ត្រីដែលអ្នកបានជ្រើសរើស។

**ការរៀបចំ** ៖

- អ្នកត្រូវមានមួយឈុតដែលបានធ្វើរួចរាល់ សម្រាប់បង្ហាញក្មេងៗ។
- ដាក់សម្ភារសម្រាប់ធ្វើឧបករណ៍តន្ត្រីមួយមុខមួយ នៅកន្លែងដែលផ្សេងៗពីគ្នានៅក្នុងថ្នាក់។

**សេក្តីណែនាំ៖**

1. ប្រាប់ក្មេងៗថា៖ ថ្ងៃនេះកូនៗនឹងធ្វើឧបករណ៍ជាមួយអ្នកគ្រូទាំងអស់គ្នា។
2. បង្ហាញឧបករណ៍តន្ត្រីទាំង ៦មុខដែលធ្វើរួចឱ្យក្មេងៗមើល។

**សេចក្តីណែនាំរបៀបបង្កើតឧបករណ៍តន្ត្រី៖**

| | |
|---|---|
|  | **<u>ស្គរ៖</u>**<br>• កំប៉ុងទឹកដោះគោ ឬ បំពង់ឫស្សី<br>• កៅស៊ូកង ឬ ខ្សែសម្រាប់ចង<br>• ប៉ោងប៉ាង<br>ចង់ប៉ោងប៉ោងពីលើមាត់កំប៉ុង ឬ បំពង់ឫស្សីដោយប្រើខ្សែ ឬ កៅស៊ូកង ចងឱ្យជាប់ជាការស្រេច។ |

| | |
|---|---|
|  | **<u>ចង្រឹង៖</u>**<br>• ស្លាបព្រាជ័រ<br>• ស៊ុតជ័រ<br>• អង្ករ<br>• ស្កុត<br>ដាក់អង្ករមួយចំនួនទៅក្នុងស៊ុតជ័របន្ទាប់មកដាក់វានៅចំកណ្តាលស្លាបព្រាជ័រទាំង២ បន្ទាប់មកបិទវាដោយប្រើស្កុតរុំឱ្យបានមាំ ដែលអាចក្រវី ឬ ក្រឡុកវាបាន ជាការស្រេច។ |
|  | **<u>កាចែ៖</u>**<br>• ឈើការ៉េម២ដើម<br>• កៅស៊ូកង២<br>• ឈើចាក់ធ្មេញ ២<br>• ក្រដាសដែលកាត់រួចដែលមានទំហំប៉ុននឹងឈើការ៉េមដែរ<br>ដាក់ក្រដាសនៅកណ្តាលបន្ទះឈើការ៉េមទាំង២នោះ។ បន្ទាប់មកប្រើកៅស៊ូកងចងវាម្ខាងសិន និងបន្ទាប់មកទៀតសូកឈើចាក់ធ្មេញកល់ទាំងសងខាង និងចងកៅស៊ូទាំង ២ទាំងសងខាង គឺជាការស្រេច។ |
|  | **<u>ក្រឡុក៖</u>**<br>• ដបជ័រមួយចំនួន<br>• គ្រាប់សណ្តែកដែលមានទំហំផ្សេងៗពីគ្នា<br>ដាក់គ្រាប់សណ្តែកទៅក្នុងដបជ័រដែលមាន ទំហំផ្សេងៗពីគ្នា ទៅដបនីមួយៗ។បន្ទាប់មកក្រឡុកវាថាតើវាមានសម្លេងខុសគ្នាដែរឬទេជាការស្រេច។ |

| | |
|---|---|
|  | **<u>ផ្លុំទឹកក្នុងដបៈ</u>**<br>● ដបទឹក<br>● ទុយោទឹក<br>● ទឹក<br>ដាក់ទឹកចូលដបទឹកឱ្យពេញ។ បន្ទាប់មកដាក់ទុយោចូល និងបន្ទាប់មកទៀត ផ្លុំដោយលើកទុយោចុះឡើង ចុះឡើង ថាវាមានសម្លេងខុសគ្នាដែរ ឬទេជាការស្រេច។ |
|  | **<u>ហ្គីតា</u>**<br>● ប្រអប់ដាក់ម្ហូបដែលមានទំហំល្មម (ប្រអប់ក្រដាសកាតុង)<br>● កៅស៊ូកងដែលមានកម្រាស់ខុសៗគ្នា<br>សូកប្រអប់ដាក់ម្ហូបទៅនឹងកៅស៊ូកងដែលមានកម្រាស់ខុសគ្នានោះ តាមលំដាប់លំដោយ។ ធ្វើវាឱ្យដូចជាខ្សែហ្គីត។ |

3. សួរក្មេងថាៈ តើឧបករណ៍តន្ត្រីមួយណាដែលកូនៗចង់បង្កើត? (ប្រសិនបើមានក្មេងៗច្រើនចង់ធ្វើដូចគ្នា អាចជ្រើសរើសធ្វើឧបករណ៍ផ្សេងៗទៀតបាន)
4. បន្ទាប់មកឱ្យក្មេងទៅកាន់កន្លែងដែលបង្កើតឧបករណ៍ផ្សេងៗគ្នាតាមដែលខ្លួនបានជ្រើសរើស។
5. អ្នកគ្រូនឹងជួយកូនៗធ្វើឧបករណ៍ទាំងនេះ(អ្នកត្រូវដើរជុំវិញក្មេងៗ)។
6. បន្ទាប់ពីក្មេងៗធ្វើឧបករណ៍ទាំងនេះរួច អាចឱ្យក្មេងៗលេងវាបាន។
7. ប្រាប់ក្មេងៗថាៈ កូនៗត្រូវទុកឧបករណ៍ទាំងនេះឱ្យបានល្អ ពីព្រោះ ល្បែងបង្កើតឧបករណ៍តន្ត្រីនេះ ទុកសម្រាប់លេងនៅក្នុងល្បែងលេងឧបករណ៍តន្ត្រីពេលក្រោយម្តងទៀត។